Cambodia Climate Change Alliance (CCCA)

Implemented by: Supported by:

MoE European Union Cambodia Danida Sida

គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ

**មូលនិធិប្រែប្រួលអាកាសធាតុនៃសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា**

# ការប្រកាសទទួលសំណើគម្រោង

**ជំនួយលេខ** #: CCCA-TF 2012/01

សម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (Cambodia Climate Change Alliance, CCCA) គឺជាកម្មវិធីទូលំទូលាយបែបច្នៃប្រឌិតថ្មីមួយ សម្រាប់ឆ្លើយតបនឹងបញ្ហាប្រែប្រួលអាកាសធាតុ និងហានិភ័យនៃគ្រោះមហន្តរាយនៅកម្ពុជា។ កម្មវិធីនេះជាកិច្ចផ្តួចផ្តើមពហុម្ចាស់ជំនួយដែលបានទទួលមូលនិធិពីសហភាពអឺរ៉ុប (EU), ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសស៊ុយអែដ (Sida), ទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិនៃប្រទេសដាណឺម៉ាក (Danida) និងកម្មវិធីអភិវឌ្ឍន៍សហប្រជាជាតិ (UNDP)។ កិច្ចផ្តួចផ្តើមនេះស្ថិតនៅក្រោមការដឹកនាំនៃគណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុនៃរាជរដ្ឋាភិបាលកម្ពុជា ដែលជាស្ថាប័នរដ្ឋាភិបាលទទួលបន្ទុកសម្របសម្រួលការរៀបចំ និងអនុវត្តគោលនយោបាយ ផែនការ និងវិធានការនានា សំដៅឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ។

មូលនិធិប្រែប្រួលអាកាសធាតុនៃ CCCA ត្រូវបានបង្កើតឡើងនៅក្រោម CCCA សំដៅការទាក់ទាញការចូលរួមរបស់ដៃគូអភិវឌ្ឍន៍នានា ហើយជាមូលនិធិដែលបានមកពីពហុម្ចាស់ជំនួយ ដើម្បីផ្តល់ធនធានសម្រាប់ការកសាងសមត្ថភាពសម្រាប់ការងារប្រែប្រួលអាកាសធាតុ នៅក្នុងរដ្ឋាភិបាលថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន។

**តាមរយៈមូលនិធិប្រែប្រួលអាកាសធាតុនៃ CCCA គណៈកម្មាធិការជាតិគ្រប់គ្រងការប្រែប្រួលអាកាសធាតុ សូមអញ្ជើញភាគីពាក់ព័ន្ធដាក់ជូនសំណើខ្លីសម្រាប់រៀបចំគម្រោងបន្សាំ ដែលគាំទ្រដល់ការអភិវឌ្ឍសមត្ថភាព និងការពង្រឹងស្ថាប័នដើម្បីដោះការប្រែប្រួលអាកាសធាតុ ដើម្បីជានាឲ្យមានការធ្វើសមាហរណកម្មការប្រែប្រួលអាកាសធាតុទៅក្នុងគោលនយោបាយ ផែនការកម្មវិធីនានា និងដើម្បីលើកកំពស់ចំណេះដឹង និងការយល់ដឹងពីការប្រែប្រួលអាកាសធាតុនៅកម្ពុជា។**

## លក្ខខណ្ឌចាំបាច់សម្រាប់ដាក់សំណើ

1. គម្រោងត្រូវផ្តោតជាសំខាន់ លើការពង្រឹងស្ថាប័នរបស់រដ្ឋាភិបាលនៅថ្នាក់ជាតិ ឬថ្នាក់ក្រោមជាតិ នៅក្នុងវិស័យដូចតទៅ ៖ **កសិកម្ម ព្រៃឈើ ជលផល ធនធានទឹក សុខាភិបាល ហេដ្ឋារចនាសម្ព័ន្ធ និងឧតុនិយម។**
2. គម្រោងដែលបានផ្សារភ្ជាប់ភាពធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុជាមួយបញ្ហាចម្រុះ ដូចជា ៖ យេនឌ័រ ការកាត់បន្ថយភាពក្រីក្រ ជីវៈចម្រុះ អភិបាលកិច្ច ការអភិវឌ្ឍដោយផ្អែកលើសហគមន៍ និងប្រសិទ្ធិភាពនៃការប្រើប្រាស់ជំនួយ។
3. សំណើខ្លីរបស់គម្រោង គួររួមបញ្ចូលនូវសកម្មភាពអនុវត្តបង្ហាញនៅមូលដ្ឋានមួយចំនួន សំដៅលើកកំពស់ភាពធន់ទ្រាំទៅនឹងការប្រែប្រួលអាកាសធាតុ នៅក្នុងវិស័យដែលបានកំណត់ខាងលើ។
4. ស្ថាប័នដែលមានសិទ្ធដាក់សំណើរួមមាន ស្ថាប័នរដ្ឋាភិបាលតែឯង ឬអង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងភាពជាដៃគូជាមួយរដ្ឋាភិបាល (សូមអានគោលការណ៍ណែនាំលំអិតស្តីពីការដាក់ពាក្យសុំ)។
5. ថវិកាគម្រោងមិនត្រូវលើសពី ៣០០០០០ (៣ សែនដុល្លារ) អាមេរិក។ សម្រាប់អ្នកដាក់ពាក្យសុំ ជាអង្គការសង្គមស៊ីវិល ថវិកាដែលនឹងផ្តល់ជូនមិនលើសពី១៥០០០០ (១សែនប្រាំពាន់) ដុល្លារអាមេរិក។
6. រយៈអនុវត្តគម្រោងមិនលើសពី១៥ ខែ។

ភាគីដែលមានចំណាប់អារម្មណ៍ **អាចស្នើសុំសេចក្តីប្រកាសទទួលសំណើពេញលេញ** និង **គោលការណ៍ណែនាំពីការដាក់ពាក្យសុំ** តាមអស័យដ្ឋាន www.camclimate.org.kh។

ដើម្បីដាក់សំណើខ្លីរបស់គម្រោង អ្នកដាក់ពាក្យសុំត្រូវបញ្ជូនឯកសារដែលពាក់ពន្ធ័ទាំងអស់ដោយភ្ជាប់មកជាមួយ CD-ROM ឬ USB Flashdisk ជាឯកសារទន់មួយច្បាប់ដូចគ្នា ដោយដាក់ក្នុងស្រោមសំបុត្រមានបោះត្រា មកអាស័យដ្ឋានខាងក្រោម **មិនលើសពីថ្ងៃសុក្រ ទី១ខែមិថុនា ឆ្នាំ២០១២ វេលាម៉ោង៧.០០ព្រឹក ។**

*កំនត់សំគាល់៖* **សិក្ខាសាលាណែនាំមួយស្តីពីការប្រកាសទទួលសំណើគម្រោងលើកទី** ២ និងរៀបចំឡើងនៅ **ថ្ងៃទី ៣០ ខែមេសា ឆ្នាំ ២០១២** ចាប់ផ្តើមពី **ម៉ោង៨.៣០នាទីព្រឹក** នៅសណ្ឋាគារ **Himawari** ទីក្រុងភ្នំពេញ។ ភាគីដែលមានចំណាប់អារម្មណ៍ ត្រូវចុះឈ្មោះចូលរួម ដោយផ្ញើអ៊ីម៉ែលទៅកាន់អាស័យដ្ឋានអ៊ីម៉ែលខាងក្រោម ភ្ជាប់មកជាមួយនូវឈ្មោះនិងអង្គការរបស់អ្នក។ សូមមេត្តាកត់សំគាល់ថា ដោយសារចំនួនកៅអីមានកំណត់ ស្ថាប័នមួយអាចមានតំណាងតែម្នាក់គត់ ដែលនិងត្រូវបានអនុញ្ញាតឲ្យចុះឈ្មោះចូលរួមក្នុងសិក្ខាសាលាណែនាំនេះ។

**<u>អាសយដ្ឋានទាក់ទង ៖</u>**

លេខាធិការដ្ឋានមូលនិធិប្រែប្រួលអាកាសធាតុនៃសម្ព័ន្ធភាពប្រែប្រួលអាកាសធាតុកម្ពុជា (CCCA)
ក្រសួងបរិស្ថាន
# ៤៨,មហាវិថីសម្តេចព្រះសីហនុ
រាជធានីភ្នំពេញ
អ៊ីម៉ែលៈ secretariat@camclimate.org.kh